ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០០១........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម
# ក្នុងវិស័យបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ/

- បានឃើញអនុក្រឹត្យលេខ៤៧៦អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៤អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ១០៤១ សហវ ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៣ អ.ស.ហ ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០១០ អ.ស.ហ ប្រក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០១៩ អ.ស.ហ ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- យោងតាមការអនុម័តនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ក្នុងវិស័យបរធនបាលកិច្ចពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្ម ដើម្បីធានាឱ្យបាននូវគុណភាពនៃសេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច និងអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

**ក្រមសីលធម៌វិជ្ជាជីវៈ** សំដៅដល់គោលការណ៍ តម្លៃ ស្តង់ដា ឬវិធាននានាដែលកំណត់អំពីឥរិយាបទរបស់គណនេយ្យករ និងសវនករក្នុងវិជ្ជាជីវៈរបស់ខ្លួន។

***ក្រុមហ៊ុនផ្តល់សេវាសវនកម្ម*** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។

***សវនកម្ម*** សំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យរបាយការណ៍កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់សហគ្រាសសម្រាប់គោលបំណងជាក់លាក់ណាមួយ។

## ជំពូកទី២

## ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

**ប្រការ៤.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលមានបំណងស្នើសុំការទទួលស្គាល់ពី **ន.ម.ឆ** ត្រូវដាក់ពាក្យស្នើសុំទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ឆ.** ព្រមទាំងបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម÷

១- មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.** ដែលមានសុពលភាព

២- បានបង្កើត និងមានធុរកិច្ចសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំការទទួលស្គាល់

៣- មានសវនករជារូបវន្តបុគ្គលយ៉ាងតិច ១ (មួយ) រូប ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

**ប្រការ៥.-**

សវនករជារូបវន្តបុគ្គលនៃក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលត្រូវទទួលស្គាល់ពី **ន.ម.ឆ.** ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.** ដែលមានសុពលភាព

២- ជាសមាជិកសកម្មជាសវនករប្រតិស្រុតរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក**)

៣- ត្រូវមានបទពិសោធន៍អនុវត្តការងារជាសវនករយ៉ាងតិច ៣ (បី) ឆ្នាំ

៤- ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ម.ឆ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឆ.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ឆ.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំចូលរួមត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត ដែលរៀបចំដោយ **ន.ម.ឆ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **ន.ម.ឆ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

**ប្រការ៦.-**

ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករជារូបវន្តបុគ្គលក្នុងវិស័យបរធនបាលកិច្ច មានសុពលភាព ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញការទទួលស្គាល់។

**ប្រការ៧.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករជារូបវន្តបុគ្គល ត្រូវដាក់ពាក្យស្នើសុំបន្តការទទួលស្គាល់មក **ន.ម.ធ.** ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ធ.** ឱ្យបានយ៉ាងតិច ៤៥ (សែសិបប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទការទទួលស្គាល់អស់សុពលភាព។

**ប្រការ៨.-**

**ន.ម.ធ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធការទទួលស្គាល់ ឬបន្តការទទួលស្គាល់ ដូចមានចែងក្នុងប្រការ៧ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទដែល **ន.ម.ធ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ៩.-**

បរធនបាលទាយក អ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល ឬបុគ្គលដទៃទៀត ដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច ត្រូវជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ធ.**។

## ជំពូកទី៣

## ភាតព្វកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលបានការទទួលស្គាល់

**ប្រការ១០.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករជារូបវន្តបុគ្គល ត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតកម្ពុជាដែលមានជាធរមាន។

**ប្រការ១១.-**

ក្នុងករណីចាំបាច់ **ន.ម.ធ.** អាចតម្រូវឱ្យបរធនបាល និងបុគ្គលដទៃទៀត ដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច តែងតាំងក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលបានការទទួលស្គាល់ ឬក្រុមហ៊ុនផ្សេងទៀត ឱ្យធ្វើសវនកម្មពិសេសលើផ្នែកណាមួយនៃប្រតិបត្តិការបរធនបាលកិច្ច ឬរបាយការណ៍ណាមួយតាមការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ រាល់ចំណាយសម្រាប់ការធ្វើសវនកម្មពិសេសនេះ និងចំណាយពាក់ព័ន្ធផ្សេងទៀត ជាបន្ទុករបស់បរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច។

**ប្រការ១២.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករជារូបវន្តបុគ្គលដែលទទួលបានការទទួលស្គាល់ មានកាតព្វកិច្ចដូចខាងក្រោម÷

១-ត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៤ និងប្រការ៥ នៃប្រកាសនេះ។

២-ត្រូវផ្តល់កិច្ចសហការក្នុងការពន្យល់របាយការណ៍សវនកម្ម និងផ្តល់ព័ត៌មាន ឬទិន្នន័យទាក់ទងនឹងសកម្មភាពសវនកម្ម ករណីមានការស្នើសុំដោយ **ន.ម.ធ.**។

៣-ត្រូវចែងក្នុងកិច្ចសន្យាធ្វើសវនកម្មជាមួយអតិថិជន អំពីសិទ្ធិរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករ ក្នុងការផ្តល់របាយការណ៍ និងព័ត៌មាន ឬទិន្នន័យជូន **ន.ម.ធ.**។

៤-ត្រូវផ្តល់ជូន**ន.ម.ធ.** នូវរបាយការណ៍អាជីវកម្មក្នុងវិស័យបរធនបាលកិច្ចប្រចាំឆ្នាំក្នុងរយៈពេល ៣(បី) ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទគណនេយ្យ ឬតាមការកំណត់របស់ **ន.ម.ធ.**។

៥-ត្រូវរាយការណ៍ជូន **ន.ម.ធ.** នៅពេលរកឃើញភាពមិនប្រក្រតីណាមួយដូចខាងក្រោម÷

- ក- ការគៃបន្លំ ឬកំហុសសំខាន់ៗរបស់បរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ចដែលមានផលប៉ះពាល់ដល់ការគ្រប់គ្រង ចាត់ចែង និងការថែរក្សាបរធន ឬប៉ះពាល់ដល់ប្រយោជន៍បុគ្គលពាក់ព័ន្ធដទៃទៀត។
- ខ- ការបាត់បង់ ឬការបាត់បង់ជាសក្តានុពលសរុបចាប់ពី ១០(ដប់) ភាគរយនៃទ្រព្យសកម្មសរុបរបស់បរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច។
- គ- ទ្រព្យសកម្មរបស់បរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច មិនគ្រប់គ្រាន់សម្រាប់ការទូទាត់ឱ្យម្ចាស់បំណុល។

៦-ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជូន**ន.ម.ធ.** ក្នុងរយៈពេលមិនលើសពី ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្នុងករណីណាមួយ ដូចខាងក្រោម÷

- ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម
- ទទួលទណ្ឌកម្មណាមួយដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្តីពីទណ្ឌកម្មនោះ
- ការព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្តីពីការព្យួរ ឬដកហូតនោះ
- កែប្រែលក្ខន្តិកៈក្រុមហ៊ុន ដោយត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃលក្ខន្តិកៈដែលបានកែប្រែរួចនោះ បន្ទាប់ពីទទួលបានការចុះបញ្ជីកែប្រែនៅក្រសួងពាណិជ្ជកម្ម
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក បន្ទាប់ពីមានការសម្រេចរបស់ក្រុមហ៊ុន
- មានបញ្ហាស្ថានភាពហិរញ្ញវត្ថុធ្ងន់ធ្ងរដែលអាចឈានទៅរកក្ស័យធន។

៧- ត្រូវរាយការណ៍ជូន **ន.ម.ធ.** ក្នុងករណីរកឃើញថាបរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ចមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

៨- ត្រូវផ្តល់ឯកសារពាក់ព័ន្ធ និងអនុវត្តកាតព្វកិច្ចផ្សេងទៀតដែលតម្រូវដោយ **ន.ម.ធ.**។

ករណី **ន.ម.ធ.** រកឃើញថាក្រុមហ៊ុនផ្តល់សេវាសវនកម្មបានចេញនូវរបាយការណ៍សវនកម្មដែលមិនត្រឹមត្រូវហើយបណ្តាលឱ្យមានការខូចខាតដល់បរធនបាល និងបុគ្គលដទៃទៀតដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច និងអ្នកប្រើប្រាស់របាយការណ៍សវនកម្ម ក្រុមហ៊ុនផ្តល់សេវាសវនកម្មនោះត្រូវទទួលខុសត្រូវទាត់សងស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## កម្រៃ

**ប្រការ១៣.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ ឬបន្តការទទួលស្គាល់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០(ពីររយពាន់) រៀល និងថ្លៃការទទួលស្គាល់ ឬបន្តការទទួលស្គាល់ចំនួន ១.០០០.០០០(មួយលាន) រៀល ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ១៤.-**

សវនករជារូបវន្តបុគ្គលនីមួយៗត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ ឬបន្តការទទួលស្គាល់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០(មួយរយពាន់) រៀល និងថ្លៃការទទួលស្គាល់ ឬបន្តការទទួលស្គាល់ចំនួន ២០០.០០០(ពីររយពាន់) រៀល ក្នុង ១ (មួយ) ឆ្នាំ។

**ប្រការ១៥.-**

រាល់កម្រៃការទទួលស្គាល់ ពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត ត្រូវបង់ចូលគណនីរបស់ **ន.ម.ធ.**។ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត ដែលបានបង់មក **ន.ម.ធ.** អនុលោមតាមប្រកាសនេះមិនត្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី៥
## ការព្យួរ និងការដកហូតការទទួលស្គាល់

**ប្រការ១៦.-**

**ន.ម.ធ.** អាចព្យួរការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គលក្នុងករណីដូចខាងក្រោម÷

១-**ន.ម.ឆ.** រកឃើញថា ព័ត៌មានដែលមាននៅក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬលាក់បាំងព័ត៌មាន។

២-មានបណ្ដឹងបដិសេធចំពោះលទ្ធផលសវនកម្ម។

៣-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មចេញដោយ **ន.គ.ស.** ត្រូវបានព្យួរ។

៤-ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ១៧.-**

**ន.ម.ឆ.** អាចដកហូតការទទួលស្គាល់ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គល ក្នុងករណីដូចខាងក្រោម÷

១-ចំពោះក្រុមហ៊ុនផ្ដល់សេវាសវនកម្ម

ក- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មចេញដោយ **ន.គ.ស.** ត្រូវបានដកហូត។

ខ- ផុតកាលវសាននៃការព្យួរដូចដែលមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ដោយមូលហេតុនៃការព្យួររបស់ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម នៅតែមិនទាន់បានដោះស្រាយ។

គ- ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម បានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការបន្លំព័ត៌មានសវនកម្ម ឬច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ឬមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ឃ- ប្រព្រឹត្តល្មើសនឹងកាតព្វកិច្ច ដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ។

២-ចំពោះសវនករជារូបវន្តបុគ្គល

ក- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម (រូបវន្តបុគ្គល) ពី **ន.គ.ស.** ផុតសុពលភាព។

ខ- ផុតកាលវសាននៃការព្យួរដូចដែលមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ដោយមូលហេតុនៃការព្យួររបស់សវនករនៅតែមិនទាន់បានដោះស្រាយ។

គ- សវនករបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការបន្លំព័ត៌មានរបាយការណ៍សវនកម្ម ឬច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ឬមានការពាក់ព័ន្ធនឹងសកម្មភាពលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ឃ- ប្រព្រឹត្តល្មើសនឹងកាតព្វកិច្ច ដូចមានចែងក្នុង និងប្រការ១០ នៃប្រកាសនេះ។

**ប្រការ១៨.-**

ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គល ដែលត្រូវបានព្យួរ ឬដកហូតការទទួលស្គាល់ដូចមានចែងក្នុងប្រការ១៦ និងប្រការ១៧ នៃប្រកាសនេះត្រូវបញ្ឈប់ការផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរពី **ន.ម.ឆ.**។ ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម ឬសវនករជា

រូបវន្តបុគ្គលដែលត្រូវបានព្យួរការផ្តល់សេវាសវនកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញបាន បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពី **ន.ម.ឆ.**។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ១៩.-**

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គល ដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ **ន.ម.ឆ.** អាចចាត់វិធានការរដ្ឋបាល ដូចខាងក្រោម÷

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើការទទួលស្គាល់
- ការព្យួរការទទួលស្គាល់
- ការដកហូតការទទួលស្គាល់។

**ប្រការ២០.-**

ត្រូវផាកពិន័យជាប្រាក់ពី ២០០.០០០(ពីររយពាន់) រៀល ដល់ ២០.០០០.០០០(ម្ភៃលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គល ដែលប្រព្រឹត្តល្មើសនឹងប្រការ៧ ប្រការ១០, ចំណុចទី២ ដល់ចំណុចទី៦ នៃប្រការ១២, ប្រការ១៦, ប្រការ១៧, និងប្រការ១៨ នៃប្រកាសនេះ។

ត្រូវផាកពិន័យជាប្រាក់ពី ២០០.០០០(ពីររយពាន់) រៀល ដល់ ៤០.០០០.០០០(សែសិបលាន) រៀល ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ចំពោះក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គល ដែលប្រព្រឹត្តល្មើសនឹង ចំណុចទី៧ នៃប្រការ១២, ចំណុច គ កថាខណ្ឌទី១ និងចំណុច គ កថាខណ្ឌទី២ នៃប្រការ១៧ នៃប្រកាសនេះ។

ត្រូវរងវិធានការរដ្ឋបាលណាមួយ ដូចមានចែងក្នុងប្រការ១៩ នៃប្រកាសនេះ ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ចបន្ថែមលើការផាកពិន័យដែលមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើ ចំពោះក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករជារូបវន្តបុគ្គលដែលប្រព្រឹត្តល្មើស។

**ប្រការ២១.-**

វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។



ក.ស

# ជំពូកទី៧
# អវសានប្បញ្ញត្តិ

**ប្រការ២២.-**

**ន.ម.ធ.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច និងដល់សាធារណជន។

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ២៤.-**

អគ្គនាយកនៃ **ន.ម.ធ.** ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យ **ន.ម.ធ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ **អ.ស.ហ**

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៤

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ